# ពិធីការសណ្ឋាគារ, កន្លែងសំណាក់ និងជួលរយៈពេលខ្លី: ឧបសម្ព័ន្ធ Q

**<u>ការធ្វើបច្ចុប្បន្នភាពថ្មីៗ ថ្ងៃទី 3/12/21:</u>**

- ក្រុងឡុងប៊ីច គឺបានដាក់អោយស្ថិតនៅចំណាត់ថ្នាក់ពណ៌ក្រហម ក្រោមផែនការមេរបស់រដ្ឋ ចំពោះសេដ្ឋកិច្ចដែលមានសុវត្ថិភាពជាងមុន។ ព័ត៌មានថ្មីៗ ទាក់ទងទៅនឹងការកំសាន្តសប្បាយផ្ទាល់ នៅខាងក្រៅ។ ការផ្លាស់ប្តូរនានា បានរំលេចអោយឃើញជាពណ៌លឿង។

តម្រូវការខាងក្រោមមានលក្ខណៈជាក់លាក់ចំពោះសណ្ឋាគារ, កន្លែងសំណាក់ និងឧស្សាហកម្មរយៈពេលខ្លី ដែលឥឡូវត្រូវបានអនុម័ត ឱ្យបើកដំណើរការឡើងវិញ។ ប្រតិបត្តិការសណ្ឋាគារ និងកន្លែងសំណាក់ ដែលមានកន្លែងប្រជុំធំ, សាលពិធីជប់លៀង, ឬមជ្ឈមណ្ឌលសន្និបាត, ប្រសិនបើអាចធ្វើទៅបាន, ត្រូវតែបិទតំបន់ទាំងអស់នេះ រហូតដល់សហគ្រាសនិមួយៗនៃគ្រឹះស្ថានទាំងនេះ ត្រូវបានអនុញ្ញាតិ ដោយបទបញ្ជារបស់មន្ត្រីសុខាភិបាល ឱ្យធ្វើចាប់ផ្តើមនូវប្រតិបត្តិការឡើងវិញដែលមានការកែប្រែផ្នែកខ្លះៗ ឬដំណើរការពេញលេញ។ បន្ថែមពីលើល័ក្ខខ័ណ្ឌនានា ដែលបានកំណត់លើគ្រឹះស្ថាន ឬកន្លែងស្នាក់នៅ ដោយមន្ត្រីសុខភាពរដ្ឋ, ដែលអាចរកឃើញ ឬមាននៅក្នុងគេហទំព័រ https://covid19.ca.gov/industry-guidance/, គ្រឹះស្ថានទាំងនោះ ត្រូវគោរពតាមពិធីសារនេះ។

ការជួលរយៈពេលខ្លី (“STRs”), ឬយូនីតជួលរួមគ្នា, ត្រូវបានអនុញ្ញាតិតាមបទបញ្ជានេះ, ហើយអនុលោមតាមបញ្ញត្តិ ឬបទបញ្ជានានា ដែលត្រូវបានអនុម័តដោយក្រុង ដែលគ្រប់គ្រងក្នុងការប្រតិបត្តិការនៃយូនីតជួលរយៈពេលខ្លី ឬយូនីតជួលរួមគ្នាផ្សេងៗទៀត។ យូនីតជួលរួមគ្នា, មិនកំណត់ចំពោះតែទៅលើ, STRs ឬភាគហ៊ុនចែករំលែកពេលវេលា (time-shares) អាចជួលបាន លុះត្រាតែម្ចាស់ផ្ទះ/អ្នកទទួលនៃយូនីត, ឬអ្នកណាម្នាក់ដែលមានការពាក់ព័ន្ធជាមួយម្ចាស់ផ្ទះ/អ្នកទទួលមិនកាន់កាប់ ឬរស់នៅក្នុងយូនីតនោះទេ ក្នុងកំឡុងពេលស្នាក់នៅ/ជួលនោះឡើយ; លើកលែងតែម្ចាស់ផ្ទះ/អ្នកទទួល មានចំណុចខាងក្រៅដាច់ពីគ្នា នៃច្រកចូល និងច្រកចេញ ហើយមិនចែករំលែកជាមួយភ្ញៀវ/អ្នកជួល នូវគ្រឿងបរិក្ខារប្រើប្រាស់នានា ក្នុងអំឡុងពេលស្នាក់នៅ/ជួលនោះឡើយ ដូចជាតំបន់ផ្ទះបាយ, បន្ទប់ទឹក, ឬកន្លែងរស់នៅផ្សេងទៀត។

**ការជួលរយៈពេលខ្លី, ឬយូនីតជួលរួមគ្នា, ត្រូវបានអនុញ្ញាតិដោយផ្អែកលើបទបញ្ជា ឡុងប៊ិចមានសុវត្ថិភាពជាពេលនៅផ្ទះ, និងក៏អនុលោមតាមបញ្ញត្តិ ឬបទប្បញ្ញត្តិដែលត្រូវបានអនុម័តដោយទីក្រុងឡុងប៊ិច ដែលគ្រប់គ្រងប្រតិបត្តិការរយៈពេលខ្លី ឬយូនីតជួលរួមគ្នា ផ្សេងៗទៀត។**

អ្នកគ្រប់គ្រងអចលនទ្រព្យ, ប្រតិបត្តិករថែមស៊ែរ, និងម្ចាស់អង្គភាព និងប្រតិបត្តិករយូនីតជួលផ្សេងទៀត ត្រូវបានអនុញ្ញាតិឱ្យជួលយូនីតដែលមិនជាប់ភ្ញៀវ ឬគ្មានការកាន់កាប់ ហើយមិនអាចជួលបន្ទប់ ឬកន្លែង នៅក្នុងលំនៅដ្ឋាន ដែលបានត្រូវកាន់កាប់បានទេ ដ៏រាបណា មានការជូនដំណឹងជាមុន។ លំនៅដ្ឋាន ឬយូនីត ដែលត្រូវបានជួល ខណៈពេលប្រតិបត្តិករមិនមានវត្តមានរាងកាយ ឬ

មានច្រកចេញចូលខាងក្រៅ ដាច់ដោយឡែក ដែលមិនតម្រូវឱ្យមានការប្រើប្រាស់កន្លែងរួម, ហើយបើមិនដូច្នេះទេ មិនមានការកាន់កាប់, គួរតែត្រូវបានចាត់ទុក ថាជាយូនីតដែលមានការកាន់កាប់។

ពិធីការបន្ថែម ដែលពាក់ព័ន្ធនឹងប្រតិបត្តិការសណ្ឋាគារ និងកន្លែងសំណាក់ ក៏ត្រូវអនុវត្តតាមផងដែរ៖

- ភោជនីយដ្ឋាន និងបារ
- មណ្ឌលហាត់ប្រាណ
- ហាងអ៊ុតសក់
- ហាងធ្វើក្រចក
- សេវាកម្មថែទាំផ្ទាល់ខ្លួន
- អាងហែលទឹកសាធារណៈ
- ប្រតិបត្តិការលក់រាយ
- កន្លែងការិយាល័យ
- ទីលានវាយកូនហ្គោល
- ទីធ្លាវាយកូនបាល់ ឬតិន្នីស
- ព្រឹត្តិការណ៍ផ្ទាល់នៅខាងក្រៅ (មានប្រសិទ្ធិភាពចាប់ពីថ្ងៃទី ១ ខែមេសា ឆ្នាំ២០២១)

ការប្រមូលផ្តុំសមាជិកពីគ្រួសារផ្សេងៗគ្នា, រាប់បញ្ចូលទាំង, តែមិនកំណត់លើ, ព្រឹត្តិការណ៍នានា, ពិធីជប់លៀង, ការប្រមូលផ្តុំ, ការប្រជុំ និងសន្និបាតនានា ត្រូវបានហាមឃាត់។ តំបន់នានា ដូចជាកន្លែងសន្និបាត, បន្ទប់ជួល, និងកន្លែងផ្សេងនានាទៀតសម្រាប់ព្រឹត្តិការណ៍ឯកជន ។ល។ នឹងត្រូវបិទទ្វារ រហូតដល់ការប្រមូលផ្តុំធំៗ ត្រូវបានអនុញ្ញាតឱ្យបន្តប្រតិបត្តិការដែលបានកែប្រែឡើងវិញ ឬប្រតិបត្តិការពេញលេញ តាមរយៈបទបញ្ជា និងការណែនាំជាក់លាក់មួយ។ មានការអនុញ្ញាតិអោយកំសាន្តសប្បាយផ្ទាល់ ស្របតាមការណែនាំនេះតែប៉ុណ្ណោះ។

មានប្រសិទ្ធិភាពចាប់ពីថ្ងៃទី ១ ខែមេសា ឆ្នាំ ២០២១, ព្រឹត្តិការណ៍ផ្ទាល់នៅខាងក្រៅ (ឧទាហរណ៍ កីឡា និងការសម្តែងផ្ទាល់) អាចនឹងកើតឡើងស្របតាមតម្រូវការនានា នៅក្នុងផ្នែកនេះ និងការណែនាំណាមួយ ដែលតម្រូវដោយរដ្ឋ, ដែលមាននៅលើគេហទំព័រ https://covid19.ca.gov/industry-guidance/។ ចំណុះ ឬសមត្ថភាពក្នុងព្រឹត្តិការណ៍ផ្ទាល់ខាងក្រៅ ត្រូវបានកំណត់ត្រឹម ២០% នៃការកាន់កាប់អតិបរមា។ ចំណុះនៅក្នុងបន្ទប់ ត្រូវបានកំណត់ត្រឹម ២៥% នៃការកាន់កាប់អតិបរមាក្នុងមួយបន្ទប់ ដែលមានចំនួនអតិបរមាចំនួន ១៥ នាក់ មិនអោយលើសពី ៣ គ្រួសារ ក្នុងមួយបន្ទប់។ ទីកន្លែងនោះត្រូវតែអនុវត្តកម្មវិធីធ្វើតេស្ត៍ ទៅលើកម្មករប្រចាំសប្តាហ៍ ស្របតាមការណែនាំរបស់រដ្ឋ។ ត្រូវកំណត់នូវការចូលរួមក្នុងព្រឹត្តិការណ៍ផ្ទាល់នៅខាងក្រៅ សម្រាប់តែភ្ញៀវទេសចរក្នុងរដ្ឋ តែប៉ុណ្ណោះ។ នៅតែត្រូវបានហាមឃាត់ ចំពោះព្រឹត្តិការណ៍ផ្ទាល់នៅខាងក្នុង។

លើកលែងតែ ត្រូវបានអនុញ្ញាតនៅទីនេះ, ហាមឃាត់នូវការប្រមូលផ្តុំសមាជិកពីគ្រួសារផ្សេងៗគ្នា, (ទោះបីជានៅខាងក្នុង ឬខាងក្រៅ), រាប់បញ្ចូលទាំង, តែមិនកំណត់លើ, ព្រឹត្តិការណ៍នានា, ពិធីជប់លៀង, ការប្រមូលផ្តុំ, ការប្រជុំ និងសន្និបាតនា

នា។ តំបន់នានា ដូចជាកន្លែងសន្និបាត, បន្ទប់ជួល, និងកន្លែងផ្សេងនានាទៀតសម្រាប់ព្រឹត្តិការណ៍ឯកជន ។ល។ នឹងត្រូវបិទទ្វារ រហូតដល់ការប្រមូលផ្តុំធំៗ ត្រូវបានអនុញ្ញាតឱ្យបន្តប្រតិបត្តិការដែលបានកែប្រែឡើងវិញ ឬប្រតិបត្តិការពេញលេញតាមរយៈបទបញ្ជា និងការណែនាំជាក់លាក់មួយ។

លើកលែងតែមានការអនុញ្ញាតិនៅទីនោះតែប៉ុណ្ណោះទេ បើមិនដូច្នោះ, ហាមឃាត់ភោជនីយដ្ឋាន និងបារ/រង្គសាលនៅខាងក្នុងប្រតិបត្តិការសណ្ឋាគារ និងផ្ទះសំណាក់ មិនអនុញ្ញាតឱ្យកន្លែង ឬផ្នែកណាមួយមិនអោយមាននូវការកក់ទុក ឬប្រើប្រាស់សម្រាប់ព្រឹត្តិការណ៍ ឬការជួបជុំគ្នាឡើយ។ ភោជនីយដ្ឋាន, រង្គសាល និងកន្លែងនានាស្រដៀងគ្នានេះ នៅតាមសណ្ឋាគារ និងកន្លែងស្នាក់អាស្រ័យ តម្រូវអោយគោរពតាមពិធីសារភោជនីយដ្ឋានញុំាអាហារខាងក្នុង (ឧបសម្ព័ន្ធ H) សម្រាប់ប្រតិបត្តិការ, រួមទាំងតម្រូវការនូវការកែប្រ សម្រាប់ការកំសាន្តសប្បាយផ្ទាល់ខាងក្នុង និងខាងក្រៅ ក្នុង/ជុំវិញភោជនីយដ្ឋាន ឬបារ។

អាចនឹងរៀបចំនូវពិធីរៀបអាពាហ៍ពិពាហ៍ ឬពិធីបុណ្យសពនៅខាងក្រៅ ឬខាងក្នុង អនុលោមតាម "គោលការណ៍ណែនាំឧស្សាហកម្មជំងឺ COVID-19: កន្លែងគោរពបូជា និងអ្នកផ្តល់សេវាកម្មសាសនា និងពិធីបុណ្យវប្បធម៌" ដែលចែងថា៖(១) ត្រូវរក្សាអោយបានគ្រប់ពេលវេលាទាំងអស់នូវចំងាយរាងកាយចំនួន ៦ ហ្វីត រវាងមនុស្ស ឬក្រុមមនុស្សពីគ្រួសារផ្សេងៗគ្នា; (២) អ្នកចូលរួមប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់ នូវរាល់វិធានការណ៍ គំលាតរាងកាយពីគ្នា ឬគំលាតសង្គម ដែលបានបញ្ជាដោយការិយាល័យសុខភាពឡុងប៊ីឆ, រួមទាំងការពាក់ម្រាបមុខលើមាត់ និងច្រមុះរបស់ពួកគេគ្រប់ពេលវេលាទាំងអស់; (៣) មិនមានបំរើនូវអាហារ, ភេសជ្ជៈ ឬភេសជ្ជៈមានជាតិអាល់កុលឡើយ; (៤) សមត្ថភាពខាងក្នុង ត្រូវតែបានកំណត់ត្រឹម ២៥% នៃការកាន់កាប់អតិបរមានៃទំហំខាងក្នុង។

ប្រតិបត្តិការនៅខាងក្រៅអាចដំណើរការបាន ដោយយោងតាមការណែនាំរបស់ក្រសួងសុខាភិបាល រដ្ឋកាលីហ្វ័រញ៉ា ដែលមានចំណងជើងថា "ការប្រើប្រាស់រចនាសម្ព័ន្ធបណ្តោះអាសន្ន សំរាប់ប្រតិបត្តិការអាជីវកម្មនៅខាងក្រៅ" ដែលមាននៅទីនេះ https://www.cdph.ca.gov/Programs/CID/DCDC/Pages/COVID-19/Use-of-Temporary-Structures-for-Outdoor-Business-Operations.aspx. លិខិតអនុញ្ញាតិណាមួយ ដែលបានចេញអោយដោយទីក្រុង ដែលតម្រូវអោយដំណើរការនៅខាងក្រៅ, រួមទាំងលិខិតអនុញ្ញាតិ ដែលតំរូវអោយតំឡើងតង់ណាមួយ, រានហាលជំរកព្រះអាទិត្យផ្សេងៗណាមួយ, ឬរចនាសម្ពន្ធ័ ដែលបានត្រូវប្រើប្រាស់សំរាប់ធ្វើប្រតិបត្តិការ, ត្រូវតែទទួលបាននូវលិខិតអនុញ្ញាតិជាមុនសិនមុនពេលធ្វើប្រតិបត្តិការ។

សូមកត់សំគាល់៖ ឯកសារនេះអាចត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលដែលព័ត៌មាន និងធនធាននានាបន្ថែមទៀត អាចរកបាន ដូច្នេះត្រូវប្រាកដថា នឹងពិនិត្យមើលលើគេហទំព័រឡុងប៊ិច COVID-19 នៅឯ www.longbeach.gov/covid19 ជាប្រចាំ ដើម្បីទទួលបានព័ត៌មានថ្មីៗ ចំពោះឯកសារនេះ។

បញ្ជីផ្ទៀងផ្ទាត់នេះ រួមមាននូវ៖

(1) គោលនយោបាយនានា និងការអនុវត្តនៅកន្លែងធ្វើការ ដើម្បីការពារសុខភាពនិយោជិក
(2) វិធានការណ៍នានា ដើម្បីធានាបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា
(3) វិធានការណ៍នានា ដើម្បីធានាការគ្រប់គ្រងការឆ្លង
(4) ការប្រាស្រ័យទាក់ទងជាមួយនិយោជិក និងសាធារណៈជន
(5) វិធានការណ៍នានា ដើម្បីធានាបាននូវការទទួលបាននូវសេវាកម្មចាំបាច់ ប្រកបដោយសមធម៌

ផ្នែកសំខាន់ៗទាំងប្រាំនេះ ត្រូវតែបានដោះស្រាយខណៈពេលដែលកន្លែងរបស់អ្នក អភិវឌ្ឍនូវពិធីការបើកឡើងវិញនោះ។

**អាជីវកម្មទាំងអស់ ដែលបានស្ថិតនៅក្នុងវិធានការណ៍ណែនាំខាងក្រោមនេះ ត្រូវត្រៀមជាស្រេច ដើម្បីពន្យល់ ថាតើហេតុអ្វីបានជាវិធានការណ៍ណាមួយ ដែលមិនបានត្រូវអនុវត្ត គឺមិនអាចអនុវត្តបាន ចំពោះអាជីវកម្មនេះ។**

**ឈ្មោះអាជីវកម្ម:** ______________________

**អាសយដ្ឋានកន្លែង:** ______________________

## A. គោលនយោបាយកន្លែងធ្វើការ និងវិធានការណ៍នានា ដើម្បីការពារសុខភាពនិយោជិក (គូសទាំងអស់ដែលអាចអនុវត្តចំពោះទីកន្លែង)

- ❑ មនុស្សគ្រប់រូបដែលអាចបំពេញភារៈកិច្ចការងាររបស់ពួកគេពីផ្ទះ ត្រូវបានគេណែនាំអោយធ្វើដូច្នេះ។
- ❑ បុគ្គលិកដែលងាយរងគ្រោះ (អ្នកដែលមានអាយុលើសពី ៦៥ ឆ្នាំ, អ្នកដែលមានលក្ខ័ណ្ឌសុខភាពរ៉ាំរ៉ៃ) ត្រូវបានចាត់តាំងអោយធ្វើការដែលអាចធ្វើបានពីផ្ទះ នៅពេលណាដែលអាចធ្វើទៅបាន, ហើយគួរពិភាក្សាអំពីកង្វល់ណាមួយជាមួយអ្នកផ្តល់សេវាថែទាំសុខភាព ឬសេវាកម្មសុខភាពវិជ្ជាជីវៈរបស់ពួកគេ ដើម្បីធ្វើការសម្រេចចិត្តសមស្រប ក្នុងការត្រឡប់ទៅកន្លែងធ្វើការវិញ។
- ❑ និយោជិកទាំងអស់ ត្រូវបានគេប្រាប់ថា មិនឱ្យមកធ្វើការប្រសិនបើឈឺ ឬប្រសិនបើពួកគេត្រូវបានប្រឈម ទៅនឹងអ្នកដែលមានជំងឺ COVID-19។
    - ○ ព័ត៌មានអំពីអត្ថប្រយោជន៍ នៃការឈប់សម្រាកដែលឧបត្ថម្ភដោយនិយោជក ឬរដ្ឋាភិបាល ដែលនយោជិក អាចមានសិទ្ធិទទួលបាន ដែលនឹងធ្វើឱ្យវាកាន់តែមានភាពងាយស្រួលខាងផ្នែកហិរញ្ញវត្ថុ ក្នុងពេលស្នាក់នៅផ្ទះ។ សូមមើលព័ត៌មានបន្ថែម ស្តីពីកម្មវិធីរបស់រដ្ឋាភិបាល ដែលគាំទ្រការឈប់សម្រាកឈឺ និងសំណងរបស់កម្មករសម្រាប់ជំងឺ COVID19, រួមមានសិទ្ធិឈប់សម្រាកឈឺរបស់និយោជិក ក្រោមច្បាប់ឆ្លើយតប ជំងឺខូរ៉ូណាវីរុស គ្រួសារជាចំបង និងសិទ្ធិរបស់និយោជិក ចំពោះអត្ថប្រយោជន៍សំណងរបស់កម្មករ និងការសន្មតថា ការងារដែលជាប់ទាក់ទង

នឹងជំងឺ COVID-19 ដោយអនុលោមតាម[បទបញ្ជាប្រតិបត្តិរបស់អភិបាលរដ្ឋ លេខ N-62-20។]

- នៅពេលទទួលបានដំណឹងថានិយោជិកម្នាក់ ឬច្រើននាក់ ធ្វើតេស្តវិជ្ជមាន, ឬមានរោគសញ្ញាស្របគ្នាទៅនឹងជំងឺ COVID-19 (ករណី), និយោជកត្រូវមានផែនការ ឬពិធីសារដើម្បីអោយករណីដាក់ខ្លួនគេអោយនៅឯកោនៅផ្ទះ ហើយតម្រូវអោយមាន ការដាក់អោយនៅឃ្លាតដាច់ឆ្ងាយពីគេ ខ្លួនឯងភ្លាមៗចំពោះ ឬនៃនិយោជិកទាំងអស់ ដែលមានការប្រឈមនៅនឹងកន្លែង ធ្វើការ ទៅនឹងករណី។ ផែនការរបស់និយោជក គួរតែពិចារណាលើពិធីការសម្រាប់និយោជិកដែលបានដាក់ខ្លួនអោយនៅ ឃ្លាត ដាច់ឆ្ងាយពី គេទាំងអស់មានលទ្ធភាពធ្វើតេស្ត ឬត្រូវបានធ្វើតេស្ត សំរាប់ជំងឺ COVID-19 ដើម្បីកំណត់ថា តើមាន ការប្រឈមនៅកន្លែងធ្វើ ការបន្ថែមទៀត, ដែលអាចតម្រូវឱ្យមានវិធានការណ៍ត្រួតពិនិត្យជំងឺ COVID-19 បន្ថែម។
- ក្នុងករណីដែលមានករណីចំនួន ៣ ឬច្រើនជាងនេះ ត្រូវបានរកឃើញនៅក្នុងកន្លែងធ្វើការក្នុងរយៈពេល ១៤ ថ្ងៃ និយោជកគួរតែ រាយការណ៍ពីចង្កោមហេតុការណ៍នេះ ទៅមន្ទីរសុខាភិបាល និងសេវាមនុស្សនៃទីក្រុងឡុងប៊ិច តាមលេខ ៥៦២-៥៧០-INFO។
- ការត្រួតពិនិត្យរោគសញ្ញា ត្រូវបានធ្វើឡើងមុនពេលនិយោជិកអាចចូលធ្វើការ។ ការត្រួតពិនិត្យត្រូវ តែរាប់បញ្ចូលទាំងការសួរនាំ ឬផែកឆេរទាក់ទងទៅនឹងការក្អក, ដង្ហើមខ្លី/ដង្ហក់ ឬគ្រុនក្តៅ និងរោគសញ្ញាផ្សេងទៀត ដែលបុគ្គលិកអាចនឹងកំពុងជួប ប្រទះ។ ការត្រួតពិនិត្យទាំងនេះ អាចត្រូវបានធ្វើឡើងពីចម្ងាយ ឬដោយផ្ទាល់ នៅពេលមកដល់របស់និយោជិក។
- ការត្រួតពិនិត្យសីតុណ្ហភាព គួរតែត្រូវបានធ្វើនៅកន្លែងធ្វើការ ប្រសិនបើអាចធ្វើទៅបាន។
- និយោជិកទាំងអស់ដែលមានទំនាក់ទំនងជាមួយសាធារណៈជន ឬនិយោជិកផ្សេងទៀត ក្នុងកំឡុងវេនរបស់ពួកគេ ត្រូវបានផ្តល់ជូន, ដោយឥតគិតថ្លៃ, ចំពោះគម្របមុខ។ គម្របមុខ គឺត្រូវពាក់ដោយនិយោជិកគ្រប់ពេលវេលាទាំងអស់ នៅពេលថ្ងៃធ្វើការ នៅពេលមានការប៉ះពាល់ ឬទំនងជាទាក់ទងជាមួយអ្នកដទៃ, និយោជិកមិនចាំបាច់ពាក់គម្របមុខក្រណាត់នោះទេ នៅពេលនិយោជិកនៅម្នាក់ឯង។
- និយោជិកត្រូវបានណែនាំ អំពីការប្រើប្រាស់ត្រឹមត្រូវនៃការបិទគម្របមុខ, រួមទាំងតំរូវការលាងសំអាតគម្របមុខរបស់ពួកគេជារៀងរាល់ថ្ងៃ។
- អ្នកថែរក្សាផ្ទះ និងអ្នកផ្សេងទៀត ដែលត្រូវចូលបន្ទប់ភ្ញៀវ ត្រូវបានណែនាំឱ្យពាក់គម្របមុខក្រណាត់។
- និយោជិកត្រូវបានណែនាំឱ្យធានានូវការអនុវត្តអនាម័យដៃ រួមទាំងលាងដៃអោយបានញឹកញាប់, ប្រើទឹកធ្វើដៃអនាម័យដៃ និងប្រកាន់ខ្ជាប់ នូវការប្រើប្រាស់ស្រោមដៃឱ្យបានត្រឹមត្រូវ។
- និយោជិកត្រូវបានតំរូវអោយ និងអនុញ្ញាតិអោយមានពេលវេលាគ្រប់គ្រាន់ សម្រាប់លាងដៃរបស់ពួកគេ យ៉ាងហោច ណាស់ រៀងរាល់ ៣០ នាទីម្តង ឬនៅពេលដែលមានតំរូវការ ប្រសិនបើស្រោមដៃបានត្រូវផ្តល់អោយ។ នៅកន្លែង ដែលការលាងដៃគឺមិនអាចអនុវត្តបាន, ទឹកធ្វើអនាម័យដៃ ដែលមានជាតិអាល់កុលយ៉ាងហោចណាស់ ៦០% ត្រូវបាន ផ្តល់ទៅដល់និយោជិកជំនួសវិញ។
- និយោជិក ត្រូវបានរំលឹកឱ្យខ្ទប់ការក្អក និងកណ្តាស់ដោយក្រដាសស្តើង។ ក្រដាសស្តើងដែលបានប្រើរួច គួរតែត្រូវបានបោះចោលក្នុងធុងសំរាម និងលាងដៃភ្លាមៗជាមួយសាប៊ូ និងទឹកក្តៅ យ៉ាងហោចណាស់ ២០ វិនាទី។

- ❑ និយោជិក, អ្នកលក់ និងបុគ្គលិកចែកចាយទាំងអស់ ត្រូវបានផ្តល់នូវការណែនាំទាក់ទងនឹង ការថែរក្សាការឃ្លាតឆ្ងាយរាងកាយពីគ្នា និងការប្រើប្រាស់គម្របមុខ នៅពេលដែលនៅជុំវិញអ្នកដទៃ។
- ❑ សម្រាកបន្តបន្ទាប់គ្នា, ដោយអនុលោមតាមបទប្បញ្ញត្តិប្រាក់ឈ្នួល និងម៉ោង, ដើម្បីធានាថាប្រាំមួយ (៦) ហ្វីត រវាងនិយោជិកអាចត្រូវបានរក្សា នៅក្នុងបន្ទប់សម្រាកគ្រប់ពេលទាំងអស់។
- ❑ និយោជិកត្រូវបានហាមឃាត់ មិនឱ្យបរិភោគ ឬផឹក នៅកន្លែងណាផ្សេងទៀត នៅក្នុងកន្លែងធ្វើការ ក្រៅពីកន្លែងសំរាកដែលបានកំណត់ទុក ឬនៅក្នុងការិយាល័យឯកជន ដែលមិនត្រូវបានចែករំលែកជាមួយអ្នកដទៃ។
- ❑ និយោជិកត្រូវបានបណ្តុះបណ្តាលយ៉ាងត្រឹមត្រូវ លើរាល់គោលការណ៍ និងនីតិវិធីនៃជំងឺ COVID-19។
- ❑ ផែនការដែលសរសេរជាក់លាក់ នៅកន្លែងធ្វើការអំពីជំងឺ COVID-19 រួមទាំងការវាយតំលៃហានិភ័យ នៃតំបន់ការងារទាំងអស់ ត្រូវបានបង្កើតឡើង។
- ❑ អ្នកដែលត្រូវបានចាត់តាំង ត្រូវបានគេកំណត់អត្តសញ្ញាណ ដើម្បីអនុវត្តនូវផែនការ។
- ❑ និយោជិកត្រូវបានបណ្តុះបណ្តាល អំពីការប្រើប្រាស់ត្រឹមត្រូវ នៃផលិតផលសំអាត និងរំងាប់មេរោគ រួមទាំងតម្រូវការ Cal/OSHA សម្រាប់ការប្រើប្រាស់ ប្រកបដោយសុវត្ថិភាព។ និយោជិកត្រូវបានគេផ្តល់ឱ្យ នូវអៀមការពារខោអាវ, ស្រោមដៃ និងឧបករណ៍ការពារផ្សេងៗទៀត តាមតម្រូវការរបស់ផលិតផល។

- ❑ បន្ទប់សំរាក, បន្ទប់ទឹក និងកន្លែងទូទៅផ្សេងទៀត កំពុងត្រូវបានគេសំឡាប់មេរោគជាញឹកញាប់, តាមកាលវិភាគដូចខាង ក្រោមៈ
  - ○ បន្ទប់សំរាក ____________________
  - ○ បន្ទប់ទឹក ____________________
  - ○ ផ្សេងៗ ____________________
- ❑ ថ្នាំសំឡាប់មេរោគ និងគ្រឿងផ្គត់ផ្គង់នានា សំរាប់និយោជិកទាំងអស់ អាចរកបានតាមទីតាំងនានា ដូចខាងក្រោម៖

  ____________________

- ❑ ទឹកលាងដៃសំឡាប់មេរោគមានប្រសិទ្ធិភាពប្រឆាំងជំងឺ COVID-19 សំរាប់និយោជិកទាំងអស់ អាចរកបានតាមទីតាំងនានា ដូចខាងក្រោម៖

  ____________________

- ❑ ច្បាប់ចតចំលងនៃពិធីសារនេះ ត្រូវបានចែកចាយដល់និយោជិកទាំងអស់។
- ❑ ស្រេចលើចិត្ត — ពិពណ៌នាពីវិធានការណ៍ផ្សេងទៀតៈ

  ____________________

## B. វិធានការណ៍នានា ដើម្បីធានាបាននូវគំលាតឆ្ងាយរវាងកាយពីគ្នា

- ❑ វិធានការណ៍ដើម្បីធានាបាននូវការឃ្លាតឆ្ងាយរវាងកាយពីគ្នា យ៉ាងតិចប្រាំមួយហ្វីតរវាង និងក្នុងចំណោមនិយោជិក, ភ្ញៀវ, និងសាធារណៈជនត្រូវបានអនុវត្ត, រួមទាំងតំបន់ដែលភ្ញៀវ និងនិយោជិកតំរង់ជួរ។
    - ○ នេះរួមបញ្ចូល ទាំងការប្រើរបាំងរាងកាយ ឬសញ្ញាដែលមើលឃើញដោយភ្នែក (ឧ., គូសសញ្ញាសំគាល់តាមកន្លែងជាន់ ឬសញ្ញាដើម្បីបញ្ជាក់ ពីកន្លែងដែលនិយោជិក និង/ឬភ្ញៀវគួរឈរ) ។
    - ○ នេះរាប់បញ្ចូលទាំង, ការត្រួតពិនិត្យ/ការចុះឈ្មោះចូល, ការត្រួតពិនិត្យចេញ, កន្លែងរង់ចាំជណ្តើរយន្ត, ហាងកាហ្វេ ហើយនិងកន្លែងបរិភោគអាហារ, និងតាក់ស៊ី និងខ្សែឡាន ឬចភ្លើងរំលែកគ្នាជិះ។
    - ○ របាំងរាងកាយត្រូវបានតំឡើង នៅបញ្ជរប្រតិបត្តិការទាំងអស់ ដែលជាកន្លែងមានចន្លោះចំនួយ ៦ ហ្វីត មិនអាចធ្វើទៅបាន រវាងបុគ្គលិក និងភ្ញៀវ។
- ❑ ភ្ញៀវចូលតាមទ្វារដែលត្រូវបានទុកអោយបើករហូត, ត្រូវបានប្រតិបត្តិដោយស្វ័យប្រវត្តិ ឬប្រតិបត្តិដោយដៃ ដោយនិយោជិកដែលលាងដៃយ៉ាងញឹកញាប់ និង/ឬការប្រើទឹកសំឡាប់មេរោគបានយ៉ាងត្រឹមត្រូវ។
- ❑ នីតិវិធីតម្រង់ជួររយៈកំឡុងពេលដែលមានមនុស្សច្រើនបំផុត ត្រូវបានអនុវត្ត, រាប់បញ្ចូលទាំងកន្លែងទទួលភ្ញៀវ ដែលអាចអនុវត្តបាន។ ភ្ញៀវត្រូវបានតម្រង់ជួរដើម្បីរក្សាចម្ងាយរាងកាយឃ្លាតគ្នា យ៉ាងតិចប្រាំមួយហ្វីត រវាងភាគីទាំងឡាយ។
- ❑ គ្រឿងសង្ហារិមទាំងអស់នៅទីសាធារណៈ ត្រូវបានរៀបចំ ដើម្បីបញ្ចូលគោលការណ៍ឃ្លាតឆ្ងាយរាងកាយពីគ្នា។
- ❑ វិធានការណ៍ឃ្លាតឆ្ងាយរាងកាយពីគ្នា ត្រូវបានអនុវត្តនៅក្នុងតំបន់បុគ្គលិកសម្រាក, តំបន់ត្រួតពិនិត្យឯកសណ្ឋាន, បន្ទប់បណ្តុះបណ្តាល, កន្លែងការិយាល័យចែករំលែក, បង្កួចសេវាកម្មបុគ្គលិក, និងតំបន់នានាផ្សេងទៀត ដែលមាន ដង់ស៊ីតេខ្ពស់ ដើម្បីមានចម្ងាយសមរម្យ រវាងនិយោជិក។
    - ○ កន្លែងដែលអាចធ្វើទៅបាន, កន្លែងសំរាកក្រៅផ្ទះ ដែលមានម្លប់ និងកន្លែងអង្គុយដែលធានាការឃ្លាតឆ្ងាយ រាងកាយពីគ្នា រវាងនិយោជិកត្រូវបានផ្តល់ជូន។
- ❑ សេវាកម្មបន្ទប់ភ្ញៀវ, សេវាកម្មបោកគក់ និងបោកស្ងួត, និងការបញ្ជូនឬចែកចាយគ្រឿងសំរួល ត្រូវបានធ្វើឡើងដោយប្រើពិធីសារទទួល និងចែកចាយ ដោយគ្មានការប៉ះពាល់, តាមដែលអាចធ្វើទៅបាន។
- ❑ ការរៀបចំគេហដ្ឋាន ធ្វើសេវាកម្មសំអាត ឬរៀបចំតែបន្ទប់ណា ដែលភ្ញៀវមិនមានវត្តមានតែប៉ុណ្ណោះ។
- ❑ ការប្រជុំមុនវេនរបស់និយោជិក ត្រូវបានធ្វើឡើងតាមបែបនិម្មត ឬនៅក្នុងតំបន់ដែលអនុញ្ញាតិ ដើម្បីការឃ្លាតឆ្ងាយរាងកាយពីគ្នា រវាងនិយោជិកទាំងឡាយ។
- ❑ ពេលវេលាមកដល់របស់និយោជិក ត្រូវបានរៀបចំអោយមកដល់បន្តបន្ទាប់គ្នា ដើម្បីកាត់បន្ថយបរិមាណចរាចរណ៍នៅខាងក្រោយច្រករបៀងផ្ទះ និងសេវាកម្មជណ្តើរយន្ត។
- ❑ និយោជិកត្រូវបានទំលាក់ទឹកចិត្ត ពីការប្រមូលផ្តុំគ្នា នៅតំបន់ដែលមានចរាចរណ៍ខ្ពស់ ដូចជាបន្ទប់ទឹក និងផ្លូវដើរ។ បង្កើតនូវទិសដៅផ្លូវដើរ និងផ្លូវឆ្លងកាត់សម្រាប់ចរាចរណ៍ថ្មើជើង, នៅកន្លែងដែលអាចធ្វើទៅបាន, ដើម្បីលុបបំបាត់មនុស្ស ពីការធ្វើដំណើរឆ្លងកាត់គ្នា។

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

- ❑ ទីធ្លាការិយាល័យ កន្លែងទទួលភ្ញៀវ, តំបន់ចុះឈ្មោះឬឆែកឈេចូលនៅតុខាងមុខ, តំបន់សេវាកម្មទទួលឥវ៉ាន់, និងកន្លែងផ្សេងទៀត ត្រូវបានរៀបចំឡើងវិញ, នៅពេលដែលអាចធ្វើទៅបាន, ដើម្បីធានាបាននូវកន្លែងធ្វើការ និងកន្លែងស្នាក់នៅដែលអនុញ្ញាតអោយមានចម្ងាយយ៉ាងតិចប្រាំមួយហ្វីត។
- ❑ សមត្ថភាពជណ្តើរយន្ត ត្រូវបានកំណត់ត្រឹម ៤ នាក់ ឬក្រុមគ្រួសារមួយក្នុងពេលម្តង សម្រាប់ជណ្តើរយន្តណាមួយដែលមិនអនុញ្ញាតឱ្យមានចម្ងាយរាងកាយ ៦ ហ្វីត រវាងអ្នកជិះ។ អ្នកជិះទាំងអស់ ត្រូវពាក់គម្របមុខក្រណាត់។
- ❑ និយោជិកត្រូវបានណែនាំឱ្យជៀសវាងការចាប់ដៃ និងការស្វាគមន៍ស្រដៀងគ្នា ដែលធ្វើឱ្យខូចដល់ការឃ្លាតឆ្ងាយរាងកាយពីគ្នា។
- ❑ ការទាក់ទងមនុស្សម្នាក់ទៅមនុស្សម្នាក់ សម្រាប់ការបញ្ជូនទំនិញទៅកាន់ការិយាល័យកាយសម្បទា ត្រូវបានលុបចោល, ប្រសិនបើអាចធ្វើទៅបាន។ ជៀសវាងការប៉ះប៉ិច និងក្តារឃ្លីប របស់អ្នកដទៃ។

## C. វិធានការណ៍នានា សំរាប់គ្រប់គ្រងការឆ្លង

### កន្លែងរួម (កន្លែងកត់ឈ្មោះ ឬពិនិត្យចូល, ឡបប៊ី, ជណ្តើយន្ត, ។ល។)

- ❑ ប្រព័ន្ធ HVAC គឺល្អ, កំពុងមានដំណើរការ; ដល់កម្រិតអតិបរិមាតាមដែលអាចធ្វើទៅបាន, ខ្យល់ត្រូវបានបង្កើនឡើង នៅកន្លែងរួម និងនៅបន្ទប់ភ្ញៀវ។
- ❑ ពិចារណាដំឡើងម៉ាស៊ីនសម្អាតខ្យល់ដែលមានប្រសិទ្ធិភាពខ្ពស់, ធ្វើឱ្យប្រសើរឡើងនូវតម្រងខ្យល់របស់អាគារឱ្យមានប្រសិទ្ធិភាពខ្ពស់បំផុត និងធ្វើការកែប្រែផ្សេងទៀត ដើម្បីបង្កើនបរិមាណខ្យល់ខាងក្រៅ និងខ្យល់នៅគ្រប់ការិយាល័យ, បន្ទប់ភ្ញៀវ និងកន្លែងផ្សេងទៀត។
- ❑ សម្រាប់គ្រឿងបរិក្ខារ ឬបន្ទប់ភ្ញៀវដែលមិនបានដំណើរការ, សូមបង្ហូរលាងទឹកក្តៅ និងត្រជាក់ រយៈពេលប្រាំនាទីមុនពេលបើកម្តងទៀត ដើម្បីជំនួសទឹកដែលមិនស្អាតនៅក្នុងបណ្តាញបំពង់ទឹករបស់កន្លែងឬគ្រឹះស្ថាន ដោយការផ្គត់ផ្គង់ទឹកបរិសុទ្ធ និងមានសុវត្ថិភាព។
- ❑ ផលិតផលសម្អាត និងរំងាប់មេរោគ ដែលត្រូវបានអនុម័តឱ្យប្រើប្រាស់ប្រឆាំងនឹង COVID-19 នៅលើបញ្ជីដែលមានការអនុម័ត ដោយ[ភ្នាក់ងារការពារបរិស្ថាន (EPA)] ត្រូវបានប្រើប្រាស់ តាមការណែនាំរបស់អ្នកផលិត។
  - ○ ផលិតផលរំងាប់មេរោគ នៅលើបញ្ជី N ជាមួយគ្រឿងផ្សំដែលមានសុវត្ថិភាពពីជំងឺហឺត ត្រូវបានជ្រើសរើស។
- ❑ អតិថិជន គួរតែចូលតាមទ្វារ ដែលបានបើកចំហរ ឬបើកដោយស្វ័យប្រវត្តិ, ប្រសិនបើអាចធ្វើទៅបាន។
- ❑ ម៉ាស៊ីនចែកចាយទឹកធ្វើអនាម័យដៃ (គ្មានការប៉ះពាល់, នៅពេលដែលអាចធ្វើទៅបាន) ត្រូវបានតំឡើង នៅតាមច្រកទ្វារចូលរបស់ភ្ញៀវ និងនិយោជិកសំខាន់ៗ និងតំបន់ទំនាក់ទំនងដូចជា ផ្លូវបើកបរ, តំបន់ទទួលភ្ញៀវ, បន្ទប់ទទួលភ្ញៀវសណ្ឋាគារ, ច្រកចូលភោជនីយដ្ឋាន, កន្លែងប្រជុំ និងកន្លែងសន្និបាត, កន្លែងចុះជណ្តើរយន្ត, អាងហែលទឹក, ហាងថែរក្សាសម្ផស្សនានា និងកន្លែងហាត់ប្រាណ។
- ❑ ភ្ញៀវត្រូវបានណែនាំថា ពួកគេត្រូវពាក់គម្របមុខក្រណាត់ រាល់ពេលដែលពួកគេមិនបរិភោគ និង/ឬផឹក; នេះរាប់បញ្ចូលទាំង

ការចូលទៅកាន់ទីតាំង, នៅពេលដើរនៅគ្រប់ទីកន្លែងក្នុងមជ្ឈមណ្ឌល, និងនៅពេលការប្រើប្រាស់បន្ទប់ទឹក។ នេះត្រូវអនុវត្តចំពោះមនុស្សពេញវ័យ និងកុមារអាយុលើសពី ២ ឆ្នាំ។ នេះអនុវត្តចំពោះតែអ្នកដែលមានជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃ ឬមានលក្ខណ្ឌវេជ្ជសាស្ត្រផ្សេងទៀត ដែលធ្វើឱ្យការប្រើប្រាស់គម្របមុខមានគ្រោះថ្នាក់ ត្រូវបានលើកលែងពីតម្រូវការនេះ។

- អតិថិជនដែលបដិសេធមិនពាក់គម្របមុខក្រណាត់ អាចនឹងត្រូវបានបដិសេធនូវសេវាកម្ម ហើយស្នើសុំចាកចេញ។

- ❑ អតិថិជនដែលមកដល់កន្លែងជាមួយកុមារ ត្រូវធានាថាកូនៗរបស់ពួកគេនៅក្បែរឪពុកម្តាយ, ជៀសវាងការប៉ះពាល់ជាមួយមនុស្សផ្សេងទៀត ឬរបស់របរដែលមិនមែនជារបស់ពួកគេ, ហើយពាក់គម្របមុខ ប្រសិនបើដល់អាយុត្រូវពាក់ ។
- ❑ អ្នកបំរើ, អ្នកបើករថយន្តដឹកអ្នកដំណើរ និងបុគ្គលិកផ្សេងទៀត ដែលលើកដាក់ ឬកំពុងផ្លាស់ប្តូររបស់របរប្រើប្រាស់ដោយអតិថិជន (ពែងកខ្វក់, ចាន, កន្សែង ។ល។) ត្រូវពាក់ស្រោមដៃដែលអាចបោះចោលបាន មុនពេលធ្វើការលើកដាក់។
- ❑ ប្រតិបត្តិការដោយគ្មានសាច់ប្រាក់ ត្រូវបានលើកទឹកចិត្ត។ ប្រសិនបើសមហេតុផលសម្រាប់កន្លែងលក់ម្ហូបអាហារ, អតិថិជនត្រូវបានអនុញ្ញាតិអោយអូសកាតឥណទាន/ឥណពន្ធផ្ទាល់ខ្លួនបាន, ហើយប្រដាក់អានកាត ត្រូវបានធ្វើអនាម័យរវាងការប្រើប្រាស់នៃភ្ញៀវនីមួយៗ។
- ❑ ស្រេចលើចិត្ត - រៀបរាប់ពីវិធានការណ៍ផ្សេងទៀត (ឧទាហរណ៍, ការផ្តល់ជូនតែម៉ោងសំរាប់មនុស្សចាស់, ការផ្តល់រង្វាន់លើកទឹកចិត្ត ពេលលក់មិនដាច់):

_______________________________________________________________

- ❑ បច្ចេកវិទ្យាមិនប៉ះពាល់ ត្រូវបានអនុវត្តសម្រាប់ការចុះឈ្មោះ ឬឆែកចូល, ទូទាត់ប្រាក់, ការចូលបន្ទប់ ឬធ្វើសំណើពិសេស, នៅពេលណាដែលអាចធ្វើទៅបាន។
  - កាតកូនសោរ ត្រូវបានធ្វើអនាម័យ បន្ទាប់ពីប្រើរួច។
- ❑ តាមលទ្ធភាពដែលអាចធ្វើទៅបានភ្ញៀវដែលចូលសណ្ឋាគារត្រូវបានចុះឈ្មោះក្នុងបញ្ជីឈ្មោះភ្ញៀវដែលរួមមានឈ្មោះលេខទូរស័ព្ទនិងអាស័យដ្ឋានអ៊ីមែលដែលអាចធ្វើបាននៅពេលចុះឈ្មោះ។
- ❑ ទូរស័ព្ទ, ថេប្លេត, កុំព្យូទ័រយួរដៃ, តុ, ប៊ិច និងគ្រឿងផ្គត់ផ្គង់ការងារផ្សេងទៀត ត្រូវបានសម្អាតនិងរំងាប់មេរោគមុនពេល, កំឡុងពេល និងក្រោយវេននិមួយៗ ឬពេលណាមួយ ឬក៏គ្រឿងបរិក្ខារត្រូវបានផ្ទេរ ទៅអោយបុគ្គលិកថ្មី។ នេះរួមបញ្ចូលទាំងទូរស័ព្ទ, វិទ្យុ, កុំព្យូទ័រ និងឧបករណ៍ទំនាក់ទំនងផ្សេងៗ, ស្ថានីយទូទាត់, ឧបករណ៍ប្រើប្រាស់ផ្ទះបាយ, ឧបករណ៍វិស្វកម្ម, ប៊ូតុងសុវត្ថិភាព, ក្រដាស់ពីរផ្នត់, រទេះរៀបចំគេហដ្ឋាន និងឧបករណ៍សំអាត, កូនសោរ, នាឡិកាពេលវេលានិងរបស់របរទំនាក់ទំនងផ្ទាល់ផ្សេងទៀត។
- ❑ កន្លែងធ្វើការ, តុ, និងបញ្ជរជំនួយ ត្រូវបានផ្តល់ជូននូវផលិតផលអនាម័យត្រឹមត្រូវ, រួមមានទឹកធ្វើអនាម័យដៃ និងក្រដាសជូតអនាម័យ, និងទឹកធ្វើអនាម័យដៃផ្ទាល់ខ្លួន ដល់បុគ្គលិកទាំងអស់ ដែលជួយអតិថិជនដោយផ្ទាល់។
- ❑ ម៉ាស៊ីនបូមធូលី ត្រូវបានបំពាក់ដោយតម្រង HEPA។ និយោជិកទាំងឡាយ ត្រូវប្រើម៉ាស៊ីនបូមធូលីជំនួសឱ្យការបោស កំរាលតដ្ឋដោយអំបោស, នៅពេលដែលអាចធ្វើទៅបាន។
- ❑ ការសម្អាតឱ្យបានហ្មត់ចត់នៅតាមតំបន់ដែលមានចរាចរណ៍ខ្ពស់ ដូចជាឡប់ប៊ីសណ្ឋាគារ, កន្លែងបញ្ជរតុចុះឈ្មោះចូលនៅខាងមុខ, តុកណ្តឹង ឬតុជញ្ជូនឥវ៉ាន់, បន្ទប់សម្រាក និងកន្លែងទទួលទានអាហារថ្ងៃត្រង់, កន្លែងផ្លាស់ប្តូរសំលៀកបំពាក់, កន្លែងផ្ទុកឥវ៉ាន់, ផ្ទះបាយ, និងតំបន់ចេញចូលនានាដែលមាន ដូចជាជណ្តើរ, ជណ្តើរដៃ, រទេះរុញ និងជណ្តើរយន្ត, និងការ

ត្រួតពិនិត្យ ត្រូវបានអនុវត្ត។

- ផ្ទៃដែលត្រូវបានប្រើជាទូទៅ ត្រូវបានសម្អាត និងរំងាប់មេរោគពេញមួយថ្ងៃ និងពេលល្ងាច, រួមមានដៃទ្វារ, ម៉ាស៊ីនលក់និងម៉ាស៊ីនទឹកកក, ឧបករណ៍ប្តូរពន្លឺ, ទូរស័ព្ទ, ទ្វារម៉ាស៊ីនបោកគក់ និងម៉ាស៊ីនសម្ងួត, រទេះដាក់ឥវ៉ាន់, ដៃទ្វាររថយន្តដឹកជញ្ជូនភ្ញៀវ, បង្គន់ និងកន្លែងលាងដៃ។
- កម្មករត្រូវបានផ្តល់ពេលវេលា ដើម្បីអនុវត្តការសម្អាត ក្នុងអំឡុងវេនរបស់ពួកគេ។
- ម៉ាស៊ីនទឹកកកដែលធ្វើដោយដៃ ត្រូវបានបិទ។
- បន្ទប់ងូតទឹកត្រូវបានសម្អាត និងរំងាប់មេរោគជាប្រចាំ ដោយប្រើថ្នាំសម្លាប់មេរោគ ដែលត្រូវបានអនុម័តដោយ EPA តាមការណែនាំរបស់អ្នកផលិត, តាមកាលវិភាគខាងក្រោម:

  ______________________________________________
- និយោជិកត្រូវបានណែនាំមិនអោយបើកទ្វារឡាន ឬឡានតាក់ស៊ី។
- អ្នកបើកបរសេវាកម្មបំរើចត, អ្នកកាន់ឥវ៉ាន់, និងអ្នកថែរក្សាគេហដ្ឋាន ត្រូវលាងដៃឱ្យបានទៀងទាត់ ក្នុងពេលវេនរបស់ពួកគេ និង/ឬប្រើទឹកធ្វើអនាម័យដៃ ឱ្យបានត្រឹមត្រូវ។
- ប្រសិនបើផ្តល់សេវាកម្មចតរថយន្តអោយ, អ្នកបើកបរសេវាកម្មចតរថយន្ត ត្រូវបានគេតម្រូវឱ្យពាក់គម្របមុខ, ស្រោមដៃ និងរក្សាគោលការណ៍ឃ្លាតឆ្ងាយរាងកាយពីគ្នា។
  - ខ្សែកូនសោរ ត្រូវដាក់ក្នុងថង់ប្លាស្ទិក។
  - ដៃចង្កូត, ប៊ូតុងបញ្ជោះ, ដៃទ្វារ, ចង្កឹះប្តូរលេខ ត្រូវបានជូតសំអាត ដោយកន្សែងជូតរំងាប់មេរោគ ដែលទទួលបាននូវការអនុម័ត។
  - អតិថិជនត្រូវបានជូនដំណឹង អំពីនីតិវិធីនៃការសម្អាត និងការរំងាប់មេរោគ។
- ប្រសិនបើមានសេវាកម្មឡានដឹក ឬយានយន្តត្រូវបានផ្តល់ជូន, ពួកគេត្រូវប្រកាន់ខ្ជាប់នូវតំរូវការសេវាកម្មចតរថយន្ត អោយ, រាប់បញ្ចូលទាំង ការសំអាត និងរំងាប់មេរោគនៅកន្លែងអង្គុយ រវាងភ្ញៀវទាំងឡាយ។
- ជម្រើសចតដោយខ្លួនឯង ត្រូវបានលើកទឹកចិត្តជាមួយភ្ញៀវ។

## បន្ទប់ភ្ញៀវ

- មនុស្សកណ្តឹង/អ្នកយួរកាន់ ត្រូវពាក់គម្របមុខ និងប្រើស្រោមដៃពេលដឹក ឬរៀបចំកាបូប ឬឥវ៉ាន់ភ្ញៀវ។ នៅពេលដែលអាចធ្វើទៅបាន, ការដឹកជញ្ជូនឥវ៉ាន់ ត្រូវដាក់ក្នុងបន្ទប់ដោយភ្ញៀវ។
- ការរៀបចំផ្ទះ គឺកាត់បន្ថយទំនាក់ទំនង ឬការប៉ះពាល់ជាមួយរបស់របរផ្ទាល់ខ្លួនរបស់ភ្ញៀវ ពេលធ្វើការសម្អាត។
- អ្នករៀបចំផ្ទះ មានប្រព័ន្ធខ្យល់ប្រតិបត្តិការ និង/ឬបើកបង្អួច នៅពេលណាដែលអាចធ្វើបាន ដើម្បីបង្កើនចរន្តខ្យល់ នៅពេលដែលដំណើរការបន្ទប់។

- ការរៀបចំផ្ទះ  ត្រូវបានអនុញ្ញាតិអោយមានពេលវេលាបន្ថែមទៀតក្នុងការសម្អាតបន្ទប់  ដើម្បីទទួលខុសត្រូវចំពោះតំរូវការនៃ

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

ការប្រុងប្រយ័ត្ន និងដើម្បីអនុញ្ញាតឱ្យពួកគេធ្វើការសំអាត និងរំងាប់មេរោគបន្ទប់ឱ្យបានហ្មត់ចត់បន្ថែមទៀតរវាងភ្ញៀវ, នៅពេលដែលមានតំរូវការ។

- ○ អ្នករៀបចំផ្ទះ ត្រូវបានផ្តល់នូវឧបករណ៍ការពារសមស្រប សម្រាប់សម្អាត។

- ❑ ផ្ទៃដែលនៅក្នុងបន្ទប់ភ្ញៀវ ត្រូវបានសម្អាត និងរំងាប់មេរោគរាល់ថ្ងៃ ក្នុងកំឡុងពេលសម្អាតបន្ទប់។ មានការលើកលែងចំពោះភ្ញៀវដែលស្នើសុំ អ្នករៀបចំផ្ទះ មិនអោយផ្តល់សេវា/សំអាតបន្ទប់ ប្រចាំថ្ងៃនោះឡើយ។
- ❑ របស់របរផ្ទះបាយ, រួមទាំងឆ្នាំង, ផ្ទះ, និងប្រដាប់ប្រដាប្រើប្រាស់ទាំងឡាយ ត្រូវបានសម្អាត និងធ្វើអនាម័យ រវាងការស្នាក់នៅរបស់ភ្ញៀវម្នាក់ៗ។
- ❑ ចានទាំងអស់ត្រូវបានលាងសម្អាត, រួមទាំងរបស់របរនៅក្នុងទូរ រវាងការស្នាក់នៅរបស់ភ្ញៀវនីមួយៗ។ ពិចារណាពីការជំនួសប្រដាប់ប្រដាប្រើប្រាស់ ដោយប្រើឧបករណ៍ហូបចុកតែម្តងប៉ុណ្ណោះ, ប្រសិនបើអាចធ្វើទៅបាន។
- ❑ ប្រដាប់ធ្វើកាហ្វេដែលផ្តល់សេវាកម្មតែម្តង ត្រូវបានផ្តល់ជូននូវពែងដែលអាចបោះចោលបាន, ជំនួសអោយគ្រឿងកែវ, កែវ ឬពែងកាហ្វេ ឬប្រដាប់ផលិតពហុពែង។
- ❑ មីនីបារ មិនមានសម្រាប់ភ្ញៀវទេ។ ផលិតផលទាំងអស់ ត្រូវបានដកចេញ។
- ❑ សាប៊ូលាងចានឱ្យបានគ្រប់គ្រាន់ និងអេប៉ុងថ្មី, ដែលមិនបានប្រើ, ក្រណាត់ជូតរំងាប់មេរោគ ត្រូវបានផ្តល់ជូនសម្រាប់ភ្ញៀវម្នាក់ៗ នៅពេលមកដល់។
- ❑ រាល់ប្រដាប់ប្រដាប្រើប្រាស់ និងតំបន់ផ្ទះបាយ, រួមទាំងផ្ទៃទូរទឹកកក, ផ្ទៃលើចង្ក្រាន, ប្រដាប់ឆុងកាហ្វេ, ថូសធើ, ផ្ទៃបន្ទប់គេង និងកន្លែងផ្សេងទៀត ត្រូវបានសម្អាតរវាងការស្នាក់នៅ របស់ភ្ញៀវនីមួយៗ។
- ❑ មិនមានរបស់របរទំនាក់ទំនងបន្តរ ដែលអាចប្រើឡើងវិញបានទេ ដូចជាទស្សនាវដ្តី, សៀវភៅមុខម្ហូប, ព័ត៌មានលំអិតនៃការទាក់ទាញក្នុងតំបន់, ប័ណ្ណគូប៉ុង, ជាដើម អាចរកបាននៅក្នុងបន្ទប់ភ្ញៀវទេ។ ព័ត៌មានសំខាន់ ត្រូវបានផ្តល់ជូនជារបស់ដែលប្រើបានតែម្តង និង/ឬបិទផ្សាយ តាមប្រព័ន្ធអេឡិចត្រូនិច។
- ❑ និយោជិកផ្នែកថែទាំផ្ទះ ត្រូវបានផ្តល់ស្រោមដៃនៅពេលដោះកំរាលពូក និងស្រោមខ្នើយចេញកខ្វក់ចេញ។ កំរាលពូក និងស្រោមខ្នើយកខ្វក់ ត្រូវបានដាក់ក្នុងថង់ប្រើប្រាស់តែម្តង, ដែលបានបិទជិត។
- ❑ កន្សែង, កំរាលពូក និងស្រោមខ្នើយទាំងអស់ ត្រូវបានយកចេញ និងសម្អាត នៅចុងបញ្ចប់នៃការស្នាក់នៅរបស់ភ្ញៀវម្នាក់ៗ ដោយមិនគិតថា តើវាមើលទៅដូចជាត្រូវបានគេប្រើរួចហើយ ឬអត់។
- ❑ រាល់កំរាលពូក និងស្រោមខ្នើយទាំងអស់ និងត្រូវបោកនៅសីតុណ្ហភាពខ្ពស់ ហើយលាងសំអាត ទៅតាមគោលការណែនាំរបស់CDC។
- ❑ ការថែទាំដែលមិនចាំបាច់ទាំងអស់ ត្រូវបានកំណត់ពេលនៅពេលបន្ទប់មិនត្រូវបានជាប់ភ្ញៀវ ឬកាន់កាប់។ ដោះស្រាយតែបញ្ហាអាសន្ន ឬបន្ទាន់ ដែលត្រូវបានអនុញ្ញាតិដោយច្បាប់ដែលអាចអនុវត្តបាន, ដែលអាចធ្វើទៅបាន។

LONGBEACH HEALTH & HUMAN SERVICES

## ការពិចារណាលើការជួលរយៈពេលខ្លី

- ❑ ការចុះឈ្មោះ ឬឆែកឆេរចូល និងឆែកឆេរចេញដោយខ្លួនឯង ឬពីចម្ងាយ ត្រូវបានផ្តល់ជូន តាមដែលអាចធ្វើទៅបាន។
- ❑ ការឆែកឆេរចូល និងឆែកឆេរចេញស្តង់ដារ ត្រូវបានអនុវត្ត ដើម្បីអនុញ្ញាតអោយមានដំណើរការសំអាត កាន់តែប្រសើររវាងការស្នាក់នៅរបស់ភ្ញៀវ។
- ❑ យូនីតជួល ត្រូវបានសម្អាត និងរំងាប់មេរោគយ៉ាងហ្មត់ចត់ បន្ទាប់ពីភ្ញៀវម្នាក់ៗស្នាក់នៅ។ នេះរួមបញ្ចូលទាំងការជូត និងការសម្អាត និងការសំឡាប់មេរោគ នៅតាមតំបន់ដែលប៉ះពាល់ខ្ពស់ទាំងអស់, រួមមានផ្លូវបង្កាន់ដៃគ្រែ, តុ, រីម៉ូតទូរទស្សន៍, កន្លែងដាក់ឥវ៉ាន់លើតុ, ក្បាលគ្រែ, ប្រដាប់ប្រដារផ្ទះបាយ, ដៃទូរទឹកកក, ដៃចង្រ្កាន, កញ្ចក់ និងរបស់របរផ្សេងៗទៀត។
- ❑ រាល់សំរាមដែលអាចកែច្នៃបាន, កាកសំណល់ និងសំរាម ត្រូវបានយកចេញ រវាងការស្នាក់នៅរបស់ភ្ញៀវ។ នេះរួមបញ្ចូលទាំង ការយកចេញ និងការបោះចោលនូវម្ហូបអាហារនានា ដែលអាចនឹងត្រូវទុកចោលក្នុងទូរទឹកកក, កន្លែងបង្អក និងបន្ទប់គេង។
    - ធុងសំរាម ត្រូវបានដាក់ជាជួរ ជាមួយថង់ដែលអាចចោលបាន។
- ❑ ល្អី ឬកញ្ជេរដាក់របស់របរបោកគក់ ត្រូវលាងសម្អាត និងរំងាប់មេរោគ បន្ទាប់ពីប្រើរួចម្តងៗ។
    - ល្អី ឬកញ្ជេរត្រូវបានតម្រង់ជួរជាមួយថង់ ឬស្បោង ដែលអាចទាំងបោះចោលបាន ឬអាចត្រូវបានបោកគក់បាន បន្ទាប់ពីប្រើប្រាស់រួចម្តងៗ។
- ❑ កំរាលពូក និងស្រោមខ្នើយទាំងអស់ ត្រូវបានយកចេញ និងបោកគក់ រវាងការស្នាក់នៅរបស់ភ្ញៀវនីមួយៗ, រួមទាំងរបស់របរដែលមើលទៅហាកដូចជាមិនទាន់ ត្រូវបានប្រើប្រាស់រួច។
    - ប្រើស្រោមដៃពេលដោះកំរាលពូក និងស្រោមខ្នើយកខ្វក់ចេញ។ កំរាលពូក និងស្រោមខ្នើយកខ្វក់ ត្រូវបានដាក់ក្នុងថង់ដែលប្រើតែម្តង, ដែលបានបិទជិត។
    - លាងដៃជាមួយសាប៊ូ ឬប្រើទឹកធ្វើអនាម័យដៃភ្លាមៗ បន្ទាប់ពីដោះស្រោមដៃចេញ។
- ❑ មិនមានកំរាលពូក និងស្រោមខ្នើយបន្ថែម ត្រូវបានរក្សាទុកនៅក្នុងយូនីតជួលឡើយ។ កំរាលពូក និងស្រោមខ្នើយ ត្រូវបានផ្តល់ជូន តាមការស្នើសុំតែប៉ុណ្ណោះ។
- ❑ រាល់កំរាលពូក និងស្រោមខ្នើយទាំងអស់ និងត្រូវបោកនៅសីតុណ្ហភាពខ្ពស់ ហើយលាងសំអាត ទៅតាមគោលការណែនាំរបស់CDC។
- ❑ ផ្ទៃទន់ទាំងអស់ ត្រូវបានសម្អាតដោយផ្អែកលើការណែនាំរបស់អ្នកផលិត។ នេះរួមបញ្ចូលទាំងរបស់របរដូចជា កំរាលព្រំ, ពូក, វាំងនន និងគ្រឿងលំអរ។
- ❑ របស់របរផ្ទះបាយ, រួមទាំងឆ្នាំង, ផ្ទះ, និងប្រដាប់ប្រដាប្រើប្រាស់ទាំងឡាយ ត្រូវបានសម្អាត និងធ្វើអនាម័យ រវាងការស្នាក់នៅរបស់ភ្ញៀវម្នាក់ៗ។
- ❑ ចានទាំងអស់ត្រូវបានលាងសម្អាត, រួមទាំងរបស់របរនៅក្នុងទូរ រវាងការស្នាក់នៅរបស់ភ្ញៀវនីមួយៗ។ ពិចារណាពីការជំនួសប្រដាប់ប្រដាប្រើប្រាស់ ដោយប្រើឧបករណ៍ហូបចុកតែម្តងប៉ុណ្ណោះ, ប្រសិនបើអាចធ្វើទៅបាន។

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីមែល: CETASKFORCE@LONGBEACH.GOV**

- ❑ ម៉ាស៊ីនបូមធូលី ត្រូវបានបំពាក់ដោយតម្រង HEPA។ និយោជិកទាំងឡាយ ត្រូវប្រើម៉ាស៊ីនបូមធូលីជំនួសឱ្យការបោស កំរាលឥដ្ឋដោយអំបោស, នៅពេលដែលអាចធ្វើទៅបាន។
- ❑ បង្គន់បន្ទប់ទឹក, ផ្កាឈូក, អាងងូតទឹក, ធុងស្តុកទឹក, ទូរ, និងផ្ទៃ ត្រូវបានបាញ់ជាមួយឧបករណ៍សម្អាតពហុផ្ទៃ ដែលមានការអនុម័ត ប្រើប្រឆាំងនឹងជំងឺ COVID-19។ កញ្ចក់ និងកែវណាមួយ ត្រូវបានជូតឱ្យបានយ៉ាងត្រឹមត្រូវ។ កំរាលបន្ទប់ទឹក ត្រូវបានដុះសំអាត និង/ឬបូមធូលី។
- ❑ យូនីតជួលត្រូវបានផ្តល់ជូននូវសាប៊ូលាងដៃ, កន្សែងក្រដាស, ក្រដាសបង្គន់, ទឹកបាញ់រំងាប់មេរោគ ឬប្រដាប់ជូតរំងាប់មេរោគ និងទឹកធ្វើដៃអនាម័យ។
- ❑ ក្រុមហ៊ុនសម្អាតខាងក្រៅ ឬវិជ្ជាជីវៈទាំងឡាយ, នៅពេលដែលបានត្រូវប្រើ, ផ្តល់នូវការបញ្ជាក់ជាទៀងទាត់ថា បទដ្ឋាននៃការសំអាត និងការរំងាប់មេរោគ កំពុងត្រូវបានអនុវត្តតាម។
- ❑ ភ្ញៀវទាំងឡាយត្រូវបានជូនដំណឹង អំពីវិធានការណ៍សំអាត និងសុវត្ថិភាព ទាំងការស្នាក់នៅ និងកំឡុងពេលស្នាក់នៅ តាមរយៈសៀវភៅបញ្ជីព័ត៌មាន និងសៀវភៅព័ត៌មានអំពីអចលនទ្រព្យ។
- ❑ ការថែរក្សាដែលមិនចាំបាច់ទាំងអស់ ត្រូវបានកំណត់ពេល នៅពេលដែលយូនីតជួលមិនត្រូវជាប់ភ្ញៀវ។ ដោះស្រាយតែបញ្ហាអាសន្ន ឬបន្ទាន់ ដែលត្រូវបានអនុញ្ញាតិដោយច្បាប់ដែលអាចអនុវត្តបាន នៅពេលដែលអាចធ្វើទៅបាន។
- ❑ ប្រព័ន្ធ HVAC គឺល្អ, កំពុងមានដំណើរការ; ដល់កម្រិតអតិបរិមាតាមដែលអាចធ្វើទៅបាន, ខ្យល់ត្រូវបានបង្កើនឡើង។ តម្រងប្រសិទ្ធភាពច្រោះខ្ពស់ ត្រូវបានប្រើប្រាស់ និងដូរជំនួសអោយបានទៀងទាត់។

## D. វិធានការណ៍នានា ដែលទំនាក់ទំនងទៅកាន់សាធារណៈជន

- ❑ ច្បាប់ថតចំលងនៃពិធីការនេះ ត្រូវបានបិទផ្សាយនៅតាមច្រកចូលសាធារណៈ នៅតាមកន្លែងនានា។
- ❑ ភ្ញៀវទាំងឡាយ ត្រូវបានជូនដំណឹងអំពីគោលការណ៍ និងនីតិវិធីរបស់មជ្ឈមណ្ឌល មុនពេលពួកគេមកដល់។ នេះរួមបញ្ចូលទាំងសិទ្ធិក្នុងការលុបចោលការកក់ទុក សម្រាប់ពិធីជប់លៀងដែលមានអ្នកទេសចរណ៍ មានចេញរោគសញ្ញា និងនីតិវិធីពិនិត្យ ឬផែកឆេរចូលថ្មី, តម្រូវការឃ្លាតឆ្ងាយរាងកាយពីគ្នា, និងតារាងពេលវេលាការសំអាត និងការរំងាប់មេរោគ សម្រាប់កន្លែងស្នាក់នៅ, គ្រឿងបរិក្ខារសំរួល និងតំបន់រួម។
- ❑ ស្លាកសញ្ញាត្រូវបានបឹទផ្សាយ ដែលរំលឹកដល់ភ្ញៀវ និងសាធារណៈជន អោយរក្សាការឃ្លាតឆ្ងាយរាងកាយពីគ្នា ចំនួន ៦ ហ្វីត, ពាក់គម្របមុខក្រណាត់, លាងដៃ ឬប្រើទឹកធ្វើអនាម័យដៃនៅពេលចូល, និងស្នាក់នៅផ្ទះ ប្រសិនបើពួកគេមានជំងឺ ឬមានរោគសញ្ញាដែលស៊ីសង្វាក់ទៅនឹងជំងឺ COVID-19។
    - ○ ភ្ញៀវទាំងឡាយនឹងបានផ្តល់អោយនូវរបាំងមុខ នៅពេលចូលមកដល់សណ្ឋាគារ ប្រសិនបើពួកគេមិនមាន។
- ❑ ស្លាកសញ្ញាត្រូវបានបឹទផ្សាយ នៅលើជណ្តើរយន្តដែលទាក់ទងទៅនឹងចំនួនអ្នកជិះអតិបរិមារ ហើយដែលថា ត្រូវពាក់គំរបមុខ។

## E. វិធានការណ៍នានា ដែលធានានូវការទទួលបានសេវាកម្មចាំបាច់ ប្រកបដោយសមធម៌

- ❑ សេវាកម្មនានាដែលមានសារៈសំខាន់សម្រាប់អតិថិជន/ភ្ញៀវ ត្រូវបានផ្តល់អាទិភាព។
- ❑ ប្រតិបត្តិការ ឬសេវាកម្មដែលអាចត្រូវបានផ្តល់ជូនពីចម្ងាយ ត្រូវបានផ្លាស់ប្តូរនៅលើអ៊ីនធឺណិត។
- ❑ វិធានការណ៍នានា ត្រូវបានបង្កើតឡើង ដើម្បីធានានូដើម្បីធានាបាននូវការទទួលបាននូវទំនិញ និងសេវាកម្ម សម្រាប់អតិថិជនដែលមានកម្រិតនៃការចល័ត និង/ឬមានហានិភ័យខ្ពស់នៅក្នុងទីធ្លាសាធារណៈ។

**វិធានការណ៍បន្ថែមណាមួយ ដែលមិនបានដាក់បញ្ចូលខាងលើ គួរតែត្រូវបានដាក់រាយនៅលើទំព័រដាច់ដោយឡែក, ដែលអាជីវកម្ម គួរតែភ្ជាប់ជាមួយនឹងឯកសារនេះ។**

**អ្នកអាចទាក់ទងមនុស្សខាងក្រោមនេះ បើសិនជាអ្នកមានសំណួរ ឬយោបល់នានា អំពីពិធីការនេះ:**

ឈ្មោះទំនាក់ទំនងអាជីវកម្ម: ____________________
លេខទូរស័ព្ទ: ____________________
កាលបរិច្ឆេទកែប្រែចុងក្រោយ: ____________________

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីមែល: CETASKFORCE@LONGBEACH.GOV**